# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- តាមសំណើរបស់ទេសាភិបាលធនាគារជាតិនៃកម្ពុជា

### ស ម្រេ ច

**មាត្រា១.-** ត្រូវបង្កើតអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (FIU) មួយ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិនៃកម្ពុជា ។

**មាត្រា២.-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាសភាពមន្ត្រីជាន់ខ្ពស់តំណាងឱ្យក្រសួង ស្ថាប័ន ដូចខាងក្រោម :

១- តំណាងធនាគារជាតិនៃកម្ពុជា..........ប្រធាន

២- តំណាងក្រសួងយុត្តិធម៌..........សមាជិក

៣- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី..........សមាជិក

៤- តំណាងក្រសួងមហាផ្ទៃ..........សមាជិក

៥- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ..........សមាជិក ។

**មាត្រា៣ .-** អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ ដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលមានឋានៈស្មើអគ្គនាយក ។

**មាត្រា៤ .-** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៥ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទេសាភិបាលធនាគារជាតិនៃកម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន ដែល ពាក់ព័ន្ធ និង សាមីខ្លួនដូចមានចែងក្នុងមាត្រា២ និងមាត្រា៣ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ